ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងរដ្ឋប្បវេណី** បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៣។

**លេខ : ០៧៥**

**ចុះថ្ងៃទី ២១_០២_២០១៣**

**សាលដីកា**

**លេខ : ៦២ "ក្រ.I សច"**

**ចុះថ្ងៃទី ២១_០៥_២០១៣**

**សមាសភាពក្រុមប្រឹក្សា**

- ឯកឧត្តម [redacted] ជាប្រធាន
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជី**

លោក [redacted]

- ដើមចោទឈ្មោះ [redacted] Yoon ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិកូរ៉េ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អាសយដ្ឋានផ្ទះលេខ ២៧៧ ផ្លូវលេខ ៣៧១ ក្រុមទី ៩ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ (ចុងបណ្តឹងឧទ្ធរណ៍)។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ។

- ចុងចម្លើយ ធនាគារ Camko Bank Limited តំណាងដោយឈ្មោះ KIM IN HONG ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អាសយដ្ឋានមជ្ឈមណ្ឌល P.G.C.T ជាន់ទី ២ ផ្លូវលេខ ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ដើមបណ្តឹងឧទ្ធរណ៍)។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

**ខ្លឹមសារនៃការទាមទារ**

ដើមចោទប្តឹងសុំទាមទារប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក, សុំទាមទារជម្ងឺចិត្តចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក, សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន និងសុំឱ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

**អង្គហេតុ និងចំណុចវិវាទ**

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] Yoon ជា ខ្លួនបានបម្រើការងារនៅធនាគារ Camko Bank Limited អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ ដើមចោទត្រូវបានធនាគារ Camko Bank Limited បញ្ឈប់ពីការងារ ដូចមាននៅក្នុងកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១។ នៅក្នុងកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនត្រង់របៀបវារៈទី ៥ ក្រុមហ៊ុនបានផ្តល់ប្រាក់បំណាច់បញ្ឈប់ពីការងារឱ្យដើម





Scanned with CamScanner

ចោទឈ្មោះ Choi Yoon ចំនួន ៤០.០០០ដុល្លារ ប្រសិនបើដើមចោទមិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយរហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១។ លុះដល់ថ្ងៃផុតកំណត់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ ធនាគារ Camko Bank Limited មិនបានផ្តល់ប្រាក់បំណាច់បញ្ឈប់ពីការងារនេះឱ្យដើមចោទ ទើបដើមចោទប្តឹងទាមទារប្រាក់នេះមកតុលាការ។

**<u>ការអះអាងរបស់គូភាគី</u>**

**<u>នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់</u>**

- **ដើមចោទឈ្មោះ**[redacted] Yoon (អវត្តមាន)
- **ចុងចម្លើយ ធនាគារ** Camko Bank Limited តំណាងដោយឈ្មោះ[redacted] HONG(អវត្តមាន)
- លោក[redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ (វត្តមាន)
- លោក[redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ (វត្តមាន)
- លោក[redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ[redacted] Yoon បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីខ្លួនបានធ្វើការនៅធនាគារ Camko Bank Limited អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ កិច្ចប្រជុំម្ចាស់ភាគហ៊ុនបានប្រព្រឹត្តឡើងដោយលើកយករបៀបវារៈ ៦ យកមកធ្វើការសម្រេច។ នៅក្នុងរបៀបវារៈទី៥ និយាយអំពីការផ្តល់ប្រាក់បំណាច់ពេលបញ្ឈប់ពីការងារសម្រាប់អភិបាល ដែលត្រូវបណ្តេញចេញ គឺកូនក្តីខ្លួនត្រូវបានទទួលទឹកប្រាក់ចំនួន ៤០០០០ដុល្លារ នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១ ក្នុងលក្ខខណ្ឌកូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារក្រោយពីការបណ្តេញចេញ។ ក្រោយពីការបណ្តេញចេញពីតួនាទីជាអភិបាលនៅក្នុងធនាគាររួចមក កូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារទេ ហើយកូនក្តីខ្លួនបានរង់ចាំទទួលប្រាក់បំណាច់នៅពេលបញ្ឈប់ការងារពីធនាគារ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ ប៉ុន្តែធនាគារមិនបានបើកប្រាក់នោះឱ្យមកកូនក្តីខ្លួនឡើយ ដោយហេតុថា លោក[redacted] Hong ជានាយកប្រតិបត្តិស្តីទីរបស់ធនាគារបានសរសេរលិខិតស្នើសុំយោបល់អាជីវកម្ម ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១១ ទៅលោក[redacted] Jong Sik ជាអ្នកគ្រប់គ្រង KDIC ដើម្បីសុំយោបល់សម្រេចឱ្យធនាគារគួរ ឬមិនគួរបង់ប្រាក់បំណាច់ ពេលបញ្ចប់ការងារឱ្យកូនក្តីខ្លួនជាអតីតអភិបាល។ ដោយកូនក្តីខ្លួនបានរង់ចាំការឆ្លើយតបនឹងសំណើនេះយូរមកហើយ ទើបកូនក្តីខ្លួនសម្រេចដាក់ពាក្យបណ្តឹងទាមទារប្រាក់បំណាច់ចំនួន ៤០០០០ដុល្លារ ពីធនាគារ Camko Bank Limited មកសាលាដំបូងរាជធានីភ្នំពេញ។ សំណូមពរ សូមក្រុមប្រឹក្សាមេធាវីតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។
- លោក[redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងហេតុថា: ឈ្មោះ[redacted] Yoon បានចូលបម្រើការងារនៅធនាគារខេមកូ ចាប់តាំងពីឆ្នាំ២០០៧ ដោយចុះកិច្ចព្រមព្រៀងកិច្ចសន្យាការងារធ្វើឡើងក្នុងមួយឆ្នាំម្តង ក្នុងនោះក្រុមហ៊ុន **ធនាគារ ខេមកូ លីមីតធីត** Camko Bank Limited បានផ្តល់ដល់លោ[redacted] Yoon ដូចជា បៀវត្សរ៍ប្រចាំឆ្នាំ ប្រាក់រង្វាន់ប្រចាំឆ្នាំ ការធានារ៉ាប់រងជីវិត និងសុខភាព ការស្នាក់នៅ ការធ្វើដំណើរ



Scanned with CamScanner

ថ្លៃសាលារៀនសម្រាប់កូនៗរបស់ឈ្មោះ [redacted] Yoon និងអត្ថប្រយោជន៍ផ្សេងៗ។ ក្រៅពីរកឃើញថា ឈ្មោះ [redacted] Yoon មានកំហុសធ្ងន់ធ្ងរ ទើបមានការសម្រេចនៅកិច្ចប្រជុំម្ចាស់ភាគហ៊ុនរបស់ធនាគារខេមខូកាលបញ្ឈប់ពីការងារជាអភិបាល ពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ ហើយបានទូទាត់ និងយល់ព្រមទទួលនូវអត្ថប្រយោជន៍ដល់គាត់ជាច្រើន ដូចជា បៀវត្សន៍ប្រចាំខែ ប្រាក់រង្វាន់ប្រចាំឆ្នាំ ការស្នាក់នៅ (ថ្លៃជួលផ្ទះ) សំបុត្រយន្តហោះធ្វើដំណើរត្រឡប់ទៅប្រទេសកូរ៉េរបស់គាត់ (រួមទាំងភរិយារបស់គាត់) ថ្លៃសាលារៀនរបស់កូនៗរបស់ឈ្មោះ [redacted] Yoon និងអត្ថប្រយោជន៍ផ្សេងៗ ហើយឈ្មោះ [redacted] Yoon បានយល់ព្រមទទួលយកការទូទាត់ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១១ ដល់ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១១ រួចរាល់អស់ហើយ ម្យ៉ាងទៀតភាគីដើមចោទបានស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ពីការងារមុខតំណែងជាអគ្គនាយករង (នាយកប្រតិបត្តិ) តាមរយៈអ៊ីម៉ែល កាលពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១ រួចរាល់ដែរ (ដូចមានជូនឯកសារពិនិត្យភស្តុតាង)។ ខ្ញុំសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះថា ចំពោះប្រាក់បំណាច់បញ្ឈប់ពីការងារជាអតីតអភិបាលតាមការទាមទាររបស់ឈ្មោះ [redacted] Yoon ចំនួន ៨០.០០០ដុល្លារអាមេរិក នោះ តាមរយៈបណ្តឹង ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ និងការសម្រេចសេចក្តីសាលក្រមលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានភាពអយុត្តិធម៌សម្រាប់កូនក្តីខ្ញុំ ដោយហេតុថា ភាគីដើមចោទពុំបានភ្ជាប់មកនូវឯកសារជាភស្តុតាងច្បាប់ដើម សម្រាប់ជាមូលដ្ឋានក្នុងការទាមទារ ទោះបីជាភាគីខ្ញុំស្នើសុំនូវភស្តុតាងដែលផ្តល់ឱ្យតាមលិខិតបញ្ជាក់សារការី "ដែលមានឈ្មោះ [redacted] SEUNG YOON ដែលបានបង្ហាញខ្លួនមុខសារការីប្រទេសកូរ៉េ បានបញ្ជាក់ថា សំណៅបកប្រែដែលភ្ជាប់មកជាមួយនេះពិតជាត្រឹមត្រូវតាមច្បាប់ដើម និងបានចុះហត្ថលេខារបស់គាត់" គឺខ្ញុំសូមបដិសេធ ដោយយោងតាមមាត្រា ៥២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា "**សកម្មភាពបណ្តឹងដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្តឹងដែលភាគីបានធ្វើដោយផ្ទាល់ខ្លួន។ ប៉ុន្តែការសារភាព និងចម្លើយដទៃទៀតស្តីពីអង្គហេតុដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ពុំមានអានុភាពឡើយ ប្រសិនបើភាគីលុបចោល ឬកែតម្រូវភ្លាមៗ**" និងមាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ រឿងនេះជាកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា តាមមាត្រា ៧៣ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា "នៃច្បាប់ស្តីពីការងារ" កថាខណ្ឌទី ៣ ចែងថា "ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់និយោជកតែម្នាក់ឯង មុនកាលកំណត់ក្រៅពីមូលហេតុដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះបើកសិទ្ធិឱ្យកម្មករនិយោជិតទទួលជម្ងឺចិត្ត ដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវបានទទួលរហូតដល់ពេលចប់កិច្ចសន្យា" ដូច្នេះ ឈ្មោះ គឺបានការប្រព្រឹត្តនូវកំហុសដ៏ធ្ងន់ធ្ងរនោះមិនអាចទទួលបាននូវប្រាក់បំណាច់បញ្ឈប់ពីការងារបានទេពីធនាគារខេមខូបានទេ។ តាមរបាយការណ៍សវនកម្មពិសេសរបស់ធនាគារខេមខូចេញដោយ Price Water House Coopers (PWC) ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០១២ ដូចមានជូនក្នុងឯកសារភស្តុតាងទី ៩ ត្រង់ទំព័រទី ២៧ ទី ២៨ និងទំព័រទី ២៩ បានបង្ហាញឱ្យឃើញថា ឈ្មោះ [redacted] Yoon មានកំហុសធ្ងន់ធ្ងរបានប្រព្រឹត្តរួមមាន ក្នុងមានឈ្មោះ [redacted] Yoon ជាអភិបាលបានឃុបឃិតលាក់បំបាំងអភិបាលឈ្មោះ [redacted] ជូយ៉ុន ត្រង់ទំព័រទី ៣ និងទំព័រទី ១១ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារក្រៅម៉ោង មិនទទួលបានប្រាក់បៀវត្សន៍ទេ ក៏ប៉ុន្តែបែរជាគាត់បាន

ទទួលប្រាក់បៀវត្សន៍ទៅវិញ ហើយបានបង្កើតក្រុមហ៊ុនចំនួន ៦ ក្រុមហ៊ុនផ្សេងទៀតដែលជាមូលហេតុនាំឱ្យមានទំនាស់ផលប្រយោជន៍របស់ធនាគារ សម្រេចការងារផ្តល់ឥណទានខុសទៅនឹងគោលការណ៍របស់ធនាគារសរុបទឹកប្រាក់មានចំនួន ២.១៦២.០៦១ដុល្លារអាមេរិក និងក្រុមហ៊ុន Chang Min Contruction មានចំនួន ៥៥០.០០០ដុល្លារអាមេរិក ហើយនឹងក្រុមហ៊ុន Shin Sun មានចំនួន ២២៥.៤៤៨ដុល្លារអាមេរិក ម្យ៉ាងទៀតត្រង់ទំព័រទី ១៥ ការចំណាយប្រាក់បំណាច់បុគ្គលិកច្រើនហួសពេក ដូចជា KEE Soon Hong និង Kang Moo Kyung (អតីតកាល) ជាប្រធាន និងជាប្រធានអគ្គនាយក ដែលបម្រើការងាររយៈពេល ៦ខែ គឺតិចជាងមួយឆ្នាំ បែរជាគាត់ទទួលបានប្រាក់បំណាច់អតីតភាពការងារជាធម្មតា ចំពោះបុគ្គលិកដែលបម្រើការងារតិចជាមួយឆ្នាំនឹងមិនទទួលបានប្រាក់បំណាច់ឡើយ។ ស្តែងចេញពីសកម្មភាពរបស់ឈ្មោះ[redacted]Yoon គឺជាការប្រព្រឹត្តឡើងនូវទង្វើ អសីលធមិ រករក្សាការសម្ងាត់វិជ្ជាជីវៈ ភាពស្មោះត្រង់ បែបនេះ ជាកំហុសយ៉ាងធ្ងន់ធ្ងរក្នុងនាមខ្លួនជាអតីតជាអភិបាល បង្កទង្វើមិនគប្បីចំពោះធនាគារខេមខូ ឈ្មោះ[redacted] Yoon បានដាក់បណ្តឹងសុំផ្អាកគណនីទាំងបីធនាគារខេមខូ ដោយចេញដីកាសម្រេចរក្សាការពារលេខ ០៧ ច ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២ ហាមឃាត់លោក[redacted] IN HONG ជាអគ្គនាយកធនាគារខេមខូ លីមីតធីត មិនឱ្យដកប្រាក់ចេញពីគណនី។ សំណូមពរ សូមឱ្យតុលាការច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ[redacted] Yoon និងសាលក្រមរដ្ឋប្បវេណីលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទាំងមូលចោល។

## <u>សំអាងហេតុ និង សេចក្តីបញ្ចប់</u>

## <u>សាលាឧទ្ធរណ៍ យល់ឃើញថា៖</u>

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១២ របស់លោក[redacted] ស៊ឹម សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងតាមកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលទាញហេតុផលដោយផ្ទាល់មាត់។

២- តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទថា កូនក្តីខ្លួនត្រូវបានភាគីធនាគារបញ្ឈប់ពីការងារ ហើយតាមកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ ត្រង់របៀបវារៈទី ៥ ចុងចម្លើយដែលជាភាគីធនាគារបានផ្តល់ប្រាក់ឱ្យកូនក្តីខ្លួនចំនួន ៤០០០០ដុល្លារអាមេរិក ប្រសិនបើកូនក្តីខ្លួនមិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយរហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១។ លុះផុតកំណត់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ ហើយ ខាងចុងចម្លើយនៅតែមិនព្រមផ្តល់ប្រាក់បំណាច់ឱ្យកូនក្តីខ្លួន ដោយហេតុនេះ ទើបកូនក្តីខ្លួនប្តឹងទាមទារប្រាក់បំណាច់នេះ។ តែតាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយថា កូនក្តីខ្លួនពិតជាបានបញ្ឈប់ដើមចោទពីការងារមែន ដោយបានផ្តល់ឱ្យដើមចោទនូវបៀវត្សប្រចាំខែ ប្រាក់រង្វាន់ប្រចាំឆ្នាំ ការស្នាក់នៅ សំបុត្រយន្តហោះធ្វើដំណើរត្រឡប់ទៅប្រទេសកូរ៉េវិញ ថ្លៃសាលារៀនសម្រាប់កូនៗរបស់ដើមចោទ និងអត្ថប្រយោជន៍ផ្សេងៗ។ ចំពោះកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ កូនក្តីខ្លួនមិនទទួលស្គាល់ឡើយ

ហើយសូមឱ្យដើមចោទបង្ហាញឯកសារដើម។ ប៉ុន្តែដើមចោទមិនមានឯកសារដើមផ្តល់ឱ្យឡើយ ដោយលើកមូលហេតុថា ឯកសារដើមមាននៅខាងចុងចម្លើយ តែចំណុចនេះត្រូវបានមេធាវីចុងចម្លើយបដិសេធ ដូច្នេះ ឃើញថា ការអះអាងរបស់មេធាវីចុងចម្លើយមានលក្ខណៈត្រឹមត្រូវ តុលាការអាចពិចារណាបាន ពីព្រោះថា កំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទ ពុំមែនជាឯកសារដើម និងពុំមែនជាឯកសារផ្លូវការតាមច្បាប់ឡើយ ពីព្រោះពុំមានហត្ថលេខា និងពុំមានបោះត្រាណាមួយជាក់លាក់ឡើយ។ វាជាលិខិតដែលគ្មានទម្រង់ការជាក់លាក់ ដែលតុលាការមិនអាចជឿបានឡើយ។

៣- សាលក្រមរដ្ឋប្បវេណីលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចដោយសំអាងលើកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទដែលពុំមានការទទួលស្គាល់ពីចុងចម្លើយនោះ ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ដែលចំណុចនេះគប្បីសាលាឧទ្ធរណ៍ពិចារណាក្នុងការសម្រេចលុបចោលសាលក្រមនេះតាមច្បាប់តទៅ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១២ របស់លោក[redacted] ស៊ីម ទុកជាត្រឹមត្រូវតាមច្បាប់។

២- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១១ ក្រ២ "ន" ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៤- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៣។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងអំឡុងពេល ០១ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|

ហត្ថលេខា: [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 10 ខែ 6 ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

ជំនុំឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]